**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តសៀមរាប**
សំណុំរឿងរដ្ឋប្បវេណីលេខ ៧២ បអស
ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៤
សញ្ញាណនៃរឿងក្ដី បណ្ដឹងទាមទារប្រាក់
សាលក្រមលេខ ១៥ "ត"/២១១
ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៤

**<u>តាងនាមប្រជារាស្ត្រខ្មែរ</u>**
**<u>សាលាដំបូងខេត្តសៀមរាប</u>**

-បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈនៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤ វេលាម៉ោង៤ និង១០នាទីរសៀល ក្នុងបន្ទប់សវនាការលេខ ខ.២ អាគារ ខ នៃសាលាដំបូងខេត្តសៀមរាប ។

-កាលបរិច្ឆេទនៃការប្រកាសសាលក្រម នៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៤ វេលាម៉ោង២ និង ៣០នាទីរសៀល នៅសាលាដំបូងខេត្តសៀមរាប ។

**<u>ដោយមានសមាសភាព</u>**

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាអនុប្រធាន និងជាចៅក្រមសាលាដំបូងខេត្តសៀមរាប ។

**ក្រឡាបញ្ជីសវនការ**

លោក [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប ។

<u>សាលាដំបូងខេត្តសៀមរាប បានចេញសាលក្រមដែលមានគូភាគីដូចខាងក្រោម ៖</u>

**ដើមចោទ ៖** ឈ្មោះ [redacted] **ណារិន** ភេទប្រុស កើតនៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៨ ជនជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ននៅផ្ទះ [redacted] ។

**អ្នកតំណាងដោយអាណត្តិឲ្យដើមចោទ ៖**

លោកមេធាវី [redacted] អត្តលេខ ២៥០២ ជាសមាជិកគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធាន នៃការិយាល័យមេធាវី [redacted] មានការិយាល័យស្ថិតនៅ [redacted] ។

**សហចុងចម្លើយ ៖**

**១-ឈ្មោះ** [redacted] **ផរ៉ែត** ភេទប្រុស កើតនៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ១៩៩២ ជនជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ននៅ [redacted] ។

២-ឈ្មោះ [redacted] **ប៊ុនធឿន** ភេទប្រុស កើតនៅថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៩២ ជនជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ននៅ [redacted] ។



Scanned with CamScanner

**អ្នកតំណាងដោយអាណត្តិឲ្យសហចុងចម្លើយ ៖**

លោកមេធាវី [redacted] អត្តលេខ ២៧៧៧T ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានការិយាល័យក្រុមហ៊ុនមេធាវី [redacted] មានទីតាំងស្ថិតនៅ [redacted] ។

កម្មវត្ថុនៃពាក្យបណ្ដឹង៖ ប្ដឹងទាមទារប្រាក់ ។

(១) អង្គហេតុ ៖

ក. ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ ៖

១-បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] ផៃវ៉េត និងឈ្មោះ [redacted] ប៊ុនធឿន រួមគ្នាសងប្រាក់ដើមចំនួន ២០,៣៧៥ដុល្លារ (ពីរម៉ឺនបីរយចិតសិបប្រាំដុល្លារអាមេរិក) ទៅឲ្យដើមចោទឈ្មោះ វ៉ន ណារិន ។

២-បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] ផៃវ៉េត និងឈ្មោះ [redacted] ប៊ុនធឿន រួមគ្នាសងសំណងជម្ងឺចិត្តចំនួន ១០,០០០,០០០ រៀល (ដប់លានរៀល) ទៅឲ្យដើមចោទឈ្មោះ [redacted] ណារិន។

ខ. ខ្លឹមសារនៃសាលក្រមដែលសហចុងចម្លើយទាមទារឲ្យតុលាការចេញ ៖

-សហចុងចម្លើយទាមទារឲ្យតុលាការចេញសាលក្រមសម្រេចច្រានចោលការទាមទាររបស់ដើមចោទទាំង ២ ចំណុចខាងលើ ។

គ. ការពន្យល់ត្រួសៗ អំពីរឿងក្ដី ៖

តាមពាក្យបណ្ដឹងចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៤ របស់លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិឲ្យដើមចោទឈ្មោះ [redacted] ណារិន ថា៖ ដើមចោទឈ្មោះ [redacted] ណារិន កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ១៧០៨៤៩៦២៣ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤ មានអាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ៤២៥ ក្រុមទី១០ ភូមិវាលទ្រា ឃុំអូរតាគី ស្រុកថ្មគោល ខេត្តបាត់ដំបង បានយល់ព្រមចុះកិច្ចសន្យាផ្ដល់ប្រាក់កម្ចីចំនួន ២លើក គឺកិច្ចសន្យាផ្ដល់ប្រាក់កម្ចីចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៣ បានផ្ដល់ប្រាក់ដើមចំនួន ៥,០០០ ដុល្លារ (ប្រាំពាន់ដុល្លារអាមេរិក) ជាមួយនិងការសន្យាផ្ដល់ការប្រាក់ ៤% ក្នុងមួយខែ រយៈពេល២៤ ខែ ។ និងកិច្ចសន្យាផ្ដល់ប្រាក់កម្ចីចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ បានផ្ដល់ប្រាក់ដើមចំនួន ១០,០០០ដុល្លារ ( មួយម៉ឺនដុល្លារអាមេរិក ) ជាមួយ និងការសន្យាផ្ដល់ការប្រាក់ ៥% ក្នុងមួយខែ រយៈពេល ១ឆ្នាំ ។

កិច្ចសន្យាផ្ដល់ប្រាក់កម្ចីចំនួន ២ លើក គឺកិច្ចសន្យាផ្ដល់ប្រាក់កម្ចីចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៣ បានផ្ដល់ប្រាក់កម្ចីចំនួន ៥,០០០ដុល្លារ ( ប្រាំពាន់ដុល្លារអាមេរិក ) ជាមួយ និងការសន្យាផ្ដល់ការប្រាក់ ៤% ក្នុងមួយខែរយៈពេល ២៤ខែ ប៉ុន្តែដើមចោទមិនបានទទួលការប្រាក់ចាប់ពីខែឧសភា ឆ្នាំ២០២៣ មកម្ល៉េះ ។ ចំណែកកិច្ចសន្យាផ្ដល់ប្រាក់កម្ចីចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ បានផ្ដល់ប្រាក់ដើមចំនួន ១០,០០០ដុល្លារ ( មួយម៉ឺនដុល្លារអាមេរិក ) ជាមួយ និងការសន្យាផ្ដល់ការប្រាក់ ៥% ក្នុងមួយខែរយៈពេល ១ឆ្នាំ ដើមចោទមិនបានទទួលការប្រាក់ចាប់តាំងពីខែកក្កដា ឆ្នាំ២០២៣ ។ មូលហេតុដែលដើមចោទយល់ព្រមចុះកិច្ចសន្យា គឺដោយសារតែការសន្យាផ្ដល់ការប្រាក់ខ្ពស់ ទើបដើមចោទខ្ចីថវិការបស់គេមកដាក់ដើម្បីបានការប្រាក់ ប៉ុន្តែមកដល់ពេលនេះដើមចោទសុំដកប្រាក់ដើមមកវិញក៏មិនបានដែរ ។

(២) ការអះអាងរបស់ភាគី ៖



Scanned with CamScanner

(២-១) ដើមចោទឈ្មោះ [redacted] ណារិន បានធ្វើសេចក្ដីថ្លែងការណ៍ថា៖ ខ្លួនបានយល់ព្រមចុះកិច្ចសន្យាផ្ដល់ប្រាក់កម្ចីចំនួន ២លើក គឺកិច្ចសន្យាផ្ដល់ប្រាក់កម្ចីចុះថ្ងៃទី២៤ ខែកុម្ភៈឆ្នាំ២០២៣ បានផ្ដល់ប្រាក់ដើមចំនួន ៥,០០០ដុល្លារ( ប្រាំពាន់ដុល្លារអាមេរិក ) ជាមួយនឹងការសន្យាផ្ដល់ការប្រាក់ ៤% ក្នុងមួយខែ រយៈពេល២៤ ខែ ។ និងចុះកិច្ចសន្យាផ្ដល់ប្រាក់កម្ចីចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ បានផ្ដល់ប្រាក់ដើមចំនួន ១០,០០០ ដុល្លារ ( មួយម៉ឺនដុល្លារអាមេរិក ) ជាមួយ និងការសន្យាផ្ដល់ការប្រាក់ ៥% ក្នុងមួយខែរយៈពេល ១ឆ្នាំ ។ កិច្ចសន្យាផ្ដល់ប្រាក់កម្ចីចំនួន ២ លើក គឺកិច្ចសន្យាផ្ដល់ប្រាក់កម្ចីចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៣ បានផ្ដល់ប្រាក់ដើមចំនួន ៥,០០០ ដុល្លារ( ប្រាំពាន់ដុល្លារអាមេរិក ) ជាមួយនិងការសន្យាផ្ដល់ការប្រាក់ ៤% ក្នុងមួយខែរយៈពេល២៤ ខែ ប៉ុន្តែខ្លួនមិនបានទទួលការប្រាក់ចាប់ពីខែឧសភា ឆ្នាំ២០២៣ មកម្ល៉េះ ។ ចំណែកកិច្ចសន្យាផ្ដល់ប្រាក់កម្ចីចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ បានផ្ដល់ប្រាក់ដើមចំនួន ១០,០០០ ដុល្លារ ( មួយម៉ឺនដុល្លារអាមេរិក ) ជាមួយ និងការសន្យាផ្ដល់ការប្រាក់ ៥%ក្នុងមួយខែ រយៈពេល ១ឆ្នាំ ខ្លួនមិនបានទទួលការប្រាក់ចាប់តាំងពីខែកក្កដា ឆ្នាំ២០២៣ ។ មូលហេតុដែលខ្លួនយល់ព្រមចុះកិច្ចសន្យា គឺដោយសារតែការសន្យាផ្ដល់ការប្រាក់ខ្ពស់ទើបខ្លួនខ្ចីថវិកាបស់គេមកដាក់ដើម្បីបានការប្រាក់ ប៉ុន្តែមកដល់ពេលនេះខ្លួនសុំដកប្រាក់ដើមមកវិញក៏មិនបានដែរ ។ ថាខ្លួននៅតែប្ដឹងទាមទារឲ្យសហចុងចម្លើយសងប្រាក់មកឲ្យខ្លួនវិញដដែល ដោយសំអាងហេតុថា សហចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន ជាបុគ្គលិកក្រុមហ៊ុនប្រីលាន ស៊ីធី បានមកទំនាក់ទំនងជាមួយខ្លួនឲ្យយកប្រាក់ទៅដាក់ជាមួយក្រុមហ៊ុនដើម្បីទទួលបានការប្រាក់ខ្ពស់ ខ្លួនក៏បានផ្ទេរប្រាក់ឲ្យទៅសហចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន ផ្ទាល់តាមរយៈធនាគារអេស៊ីលីដា ប្រាក់នេះខ្លួនបានខ្ចីពីធនាគារប្រាសាក់ដែរ មិនមែនប្រាក់ផ្ទាល់ខ្លួនទេ ។

(២-២) លោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឲ្យដើមចោទ ឈ្មោះ [redacted] ណារិន បានធ្វើសេចក្ដីថ្លែងការណ៍បន្ថែមថា ៖ ខ្លួនជាមេធាវីតំណាងដោយអាណត្តិឲ្យភាគីដើមចោទខ្លួននៅតែរក្សាការប្ដឹងទាមទារដូចនៅក្នុងពាក្យបណ្ដឹងដដែល ។ ខ្លួនសុំប្ដឹងឲ្យសហចុងចម្លើយមានទំនួលខុសត្រូវ ដោយសារជាការអនុវត្តកាតព្វកិច្ច ដែលមានចែងនៅក្នុងកិច្ចសន្យាផ្ដល់ប្រាក់កម្ចីចំនួនពីរ ទីមួយកិច្ចសន្យាផ្ដល់ប្រាក់កម្ចីចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៣ និងកិច្ចសន្យាផ្ដល់ប្រាក់កម្ចីលើកទី២ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ ដែលមានប្រាក់សរុបចំនួន ១៥,០០០ ដុល្លារ ( មួយម៉ឺនប្រាំពាន់ដុល្លារអាមេរិក ) ហើយទទួលបានការប្រាក់រហូតដល់៤% ក្នុងមួយខែ ។ ហើយកូនក្ដីខ្លួនពិតជាបានផ្ទេរប្រាក់ទៅឲ្យសហចុងចម្លើយតាមរយៈគណនីធនាគារអេស៊ីលីដា ហើយដោយសារតែសហចុងចម្លើយ មិនបានអនុវត្តដែលមានចែងនៅក្នុងកិច្ចសន្យា ខ្លួនជាមេធាវីតំណាងឲ្យដើមចោទ ខ្លួនស្នើសុំឲ្យលោកចៅក្រម ឲ្យភាគីសហចុងចម្លើយអនុវត្តតាមកិច្ចសន្យាដែលមានប្រាក់ដើមចំនួន ១៥,០០០ដុល្លារ ( មួយម៉ឺនប្រាំពាន់ដុល្លារអាមេរិក) សរុបទាំងការប្រាក់ចំនួន ២០,៣៧៥ ដុល្លារ ( ពីរម៉ឺនបីរយចិតសិបប្រាំដុល្លារអាមេរិក ) និងសុំប្ដឹងទាមទារសំណងជម្ងឺចិត្តចំនួន ១០,០០០,០០០ រៀល ( ដប់លានរៀល ) ។

(២-៣) សហចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន បានធ្វើសេចក្ដីថ្លែងការណ៍ថា៖ ខ្លួនប្រានចោលមិនទទួលស្គាល់អំពីអង្គហេតុ និងមូលហេតុនៃការទាមទាររបស់ភាគីដើមចោទទេ ខ្លួនគ្រាន់តែជាអ្នកត្រូវបានដើមចោទពឹងពាក់ឲ្យខ្លួនបានដាក់ប្រាក់ចូលទៅក្រុមហ៊ុនប្រីលាន ស៊ីធី តែប៉ុណ្ណោះដើម្បីបានទទួលការប្រាក់ ដោយសារខ្លួន និងដើមចោទជាអ្នកស្គាល់គ្នា។ ដូចដែល



Scanned with CamScanner

បានបង្ហាញក្នុងភស្តុតាងរបស់ភាគីដើមចោទ ដើមចោទបានផ្ទេរប្រាក់ចូលគណនីរបស់ខ្លួនលើកទីមួយចំនួន ៥,០០០ដុល្លារ (ប្រាំពាន់ដុល្លារអាមេរិក) តាមរយៈធនាគារ អេស៊ីលីដា នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៣ និងលើកទី២ នៅថ្ងៃ២៨ ខែមីនា ឆ្នាំ២០២៣ ចំនួន ១០,០០០ ដុល្លារ ( មួយម៉ឺនដុល្លារអាមេរិក ) សរុបចំនួន ១៥,០០០ដុល្លារ ( មួយម៉ឺនប្រាំពាន់ដុល្លារអាមេរិក ) ប្រាក់ទាំងអស់ ដែលភាគីដើមចោទបានប្រគល់ឲ្យមកខ្លួន ខ្លួនបានប្រគល់ឲ្យទៅឈ្មោះ [redacted] ផៃរ៉េត អស់ហើយ តែខ្លួនមិនបានចាំថា ខ្លួនប្រគល់ជាសាច់ប្រាក់សុទ្ធ ឬក៏ផ្ទេរជាតួលេខសាច់ប្រាក់តាមធនាគារទេ ខ្លួននឹងស្រាវជ្រាវរកភស្តុតាងដើម្បីដាក់បន្ថែមទៀត ។ ខ្លួនមានតួនាទីជាបុគ្គលិកនៅក្រុមហ៊ុន ខ្លួនក៏បានដាក់ប្រាក់ចូលនៅក្នុងក្រុមហ៊ុននេះដែរ ដើម្បីបានការប្រាក់ខ្ពស់ ក៏បានឲ្យបងប្អូននិងមិត្តភក្តិដាក់ជាមួយដែរ ។ ខ្លួនទទួលស្គាល់ថា ពិតជាបានទទួលប្រាក់ទាំងពីរលើកពីដើមចោទពិតមែន តែបានប្រគល់បន្តឲ្យទៅឈ្មោះ [redacted] ផៃរ៉េត អស់ហើយ ឈ្មោះ [redacted] ផៃរ៉េត មានតួនាទីជាប្រធានផ្នែកទីផ្សារនៅក្នុងក្រុមហ៊ុន ។ ខ្លួនទទួលស្គាល់ថា ពិតជាបានចូលរួមធ្វើកិច្ច-សន្យាផ្តល់ប្រាក់កម្ចីរវាងឈ្មោះ [redacted] ផៃរ៉េត ជាប្រធានផ្នែកទីផ្សារនៃបុរីប្រ៊ីលាន ស៊ីធី និងភាគីដើមចោទពិតមែន, លើកទីមួយនៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៣ ដែលមានទឹកប្រាក់សរុបចំនួន ៥,០០០ ដុល្លារ ( ប្រាំពាន់ដុល្លារអាមេរិក ) និងលើកទីពីរនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ ដែលមានទឹកប្រាក់សរុបចំនួន ១០,០០០ដុល្លារ ( មួយម៉ឺនដុល្លារអាមេរិក ) តែក្នុងកិច្ចសន្យាខ្លួនគ្រាន់តែជាសាក្សីតែប៉ុណោះ ។ បើដើមចោទឲ្យខ្លួនសងប្រាក់ទៅដើមចោទវិញ ខ្លួនមិនយល់ព្រមទេ ព្រោះខ្លួនមិនបានយកប្រាក់របស់ដើមចោទទៅចាយវាយផ្ទាល់ខ្លួនទេ ដើមចោទបានពឹងពាក់ឲ្យខ្លួនយកប្រាក់ទៅដាក់ឲ្យក្រុមហ៊ុនដើម្បីទទួលបានការប្រាក់ ហើយខ្លួនក៏បានរៀបចំទៅតាមសំណើររបស់ដើមចោទតែប៉ុណ្ណោះ, ហើយខ្លួនក៏មិនមានប្រាក់សងទៅដើមចោទដែរ ព្រោះខ្លួនបានចាញ់បោកក្រុមហ៊ុននេះអស់ប្រាក់ផ្ទាល់ខ្លួនប្រហែលជាង ១០០,០០០ ដុល្លារ ( ដប់ម៉ឺនដុល្លារអាមេរិក) ដែរ ប្រាក់នោះ គឺខ្លួនបានមកពីទៅធ្វើកម្មកររោងចក្រនៅប្រទេសកូរ៉េ និងខ្ចីចងការយកប្រាក់ពីធនាគារ អេស៊ីលីដា ។

(២-៤) លោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឲ្យសហចុងចម្លើយឈ្មោះ [redacted] ផៃរ៉េត និងឈ្មោះ [redacted] ប៊ុនធឿន បានធ្វើសេចក្តីថ្លែងការណ៍បន្ថែមថា ៖ ខ្លួនសុំប្រានចោលការទាមទាររបស់ដើមចោទ ដែលប្តឹងទាមទារប្រាក់ដើម នៅក្នុងពាក្យបណ្តឹងចំនួន ២០,៣៧៥ ដុល្លារ (ពីរម៉ឺនបីរយចិតសិបប្រាំដុល្លារអាមេរិក) និងប្តឹងទាមទារជម្ងឺចិត្តចំនួន ១០,០០០,០០០រៀល ( ដប់លានរៀល ) ពីកូនក្តីរបស់ខ្លួន ដោយអះអាងថា ដោយសារប្រាក់ដែលដើមចោទបានដាក់មកនេះ កូនក្តីខ្លួនបានបញ្ជូនទៅក្រុមហ៊ុនដើម្បីវិនិយោគ ហើយដើមចោទបានដឹងច្បាស់អំពីការងារទាំងអស់នេះ ។ ហើយមួយទៀតដើមចោទមិនមែនទើបតែធ្វើកិច្ចការនេះជាលើកដំបូងនោះទេ គឺដើមចោទបានដឹងបានស្គាល់អំពីក្រុមហ៊ុនប្រ៊ីលាន ស៊ីធី តាំងពីនៅធ្វើការប្រទេសកូរ៉េ ពីព្រោះដើមចោទក៏ជាពលករធ្វើការនៅប្រទេសកូរ៉េដែរ ។ ដើមចោទដឹងច្បាស់ថា ប្រាក់ដែលបានដាក់មកតាមរយៈកូនក្តីខ្លួននេះ គឺជាប្រាក់សំរាប់វិនិយោគជាមួយនឹងក្រុមហ៊ុន ដើម្បីទទួលបានការប្រាក់ ហើយពាក់ពន្ធ័នឹងការធ្វើកិច្ចសន្យាផ្តល់ប្រាក់កម្ចីរវាងដើមចោទ និងកូនក្តីខ្លួននេះ គឺមិនមែនជាកិច្ចសន្យាខ្ចីប្រាក់ដែលកូនក្តីខ្លួនយកប្រាក់នេះមកប្រើប្រាស់ផ្ទាល់ខ្លួនទេ ឬជាកិច្ចសន្យាខ្ចីប្រាក់រវាងដើមចោទ និងកូនក្តីខ្លួននោះដែរ ប៉ុន្តែវាជាការណែនាំរបស់ក្រុមហ៊ុន ដើម្បីឱ្យអ្នកវិនិយោគទាំងអស់នេះមានទំនុកចិត្តទៅលើក្រុមហ៊ុន ដោយប្រើ



Scanned with CamScanner

ឈ្មោះកូនក្តីខ្លួន ដែលមានតួនាទីជាប្រធានផ្នែកទីផ្សារ ។ ដើមចោទពិតជាបានដឹងច្បាស់អំពីរបៀបចាត់ចែង ធ្វើការរបស់ក្រុមហ៊ុន ។ ក្នុងរឿងនេះខ្លួនសំណូមពរសុំឱ្យដើមចោទ និងតុលាការដាក់បន្ទុកទៅលើក្រុមហ៊ុនជាអ្នកចេញសងពីព្រោះនៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២៤ លោកស្រីប្រធាន [redacted] ចាន់ណា បានប្រកាសធានាសងប្រាក់ដើមទាំងអស់ទៅអ្នកដាក់ប្រាក់វិនិយោគជាមួយក្រុមហ៊ុន, ម្យ៉ាងទៀតកូនក្តីខ្លួន ក៏ជាជនរងគ្រោះដោយសារកូនក្តីខ្លួនបានដាក់ប្រាក់វិនិយោគជាមួយក្រុមហ៊ុនអស់ជាច្រើនដែរ ។ ថាបើយោងតាមពាក្យបណ្តឹងដែលដើមបណ្តឹងបានដាក់ និងដោយយោងតាមចម្លើយរបស់សហចុងចម្លើយឈ្មោះ [redacted] ប៊ុយឿន ដោយសារតែសហចុងចម្លើយឈ្មោះ [redacted] ផៃរ៉េត មិនបានចូលរួម ទាក់ទងក៏មិនបាន ដូច្នេះហើយមានតែចម្លើយរបស់សហចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន ដែលបានឆ្លើយនៅពេលធ្វើនីតិវិធីត្រៀមសំរាប់ការទាញហេតុផលថាបានទទួលប្រាក់ចំនួន ១៥,០០០ដុល្លារ ( មួយម៉ឺនប្រាំពាន់ដុល្លារអាមេរិក ) តាមរយៈគណនេយ្យធនាគារអេស៊ីលីដា ចំនួនពីរ ចំនួន ៥,០០០ដុល្លារ ( ប្រាំពាន់ដុល្លារអាមេរិក ) និងមួយលើកទៀតចំនួន ១០,០០០ដុល្លារ ( មួយម៉ឺនដុល្លារអាមេរិក ) មិនជំទាស់ទេ ប៉ុន្តែប្រាក់នេះបានបញ្ជូនទៅឲ្យក្រុមហ៊ុន ដើម្បីធ្វើការវិនិយោគផ្សេងៗ ។ រហូតមកដល់ពេលនេះខ្លួននៅតែទទួលស្គាល់ថា កូនក្តីខ្លួនបានទទួលប្រាក់ពីដើមចោទសរុបចំនួន ១៥,០០០ដុល្លារ (មួយម៉ឺនប្រាំពាន់ដុល្លារអាមេរិក ) ពីដើមចោទពិតប្រាដកមែន។

(៣) អំពីចំណុចវិវាទ ៖

- អង្គហេតុដែលអះអាងដោយដើមចោទ៖ ដើមចោទយល់ព្រមចុះកិច្ចសន្យាផ្តល់ប្រាក់កម្ចីជាមួយសហចុងចម្លើយចំនួន ២លើក ដែលមានប្រាក់សរុបចំនួន ១៥,០០០ ដុល្លារ (មួយម៉ឺនប្រាំពាន់ដុល្លារអាមេរិក) ។

- អង្គហេតុដែលអះអាងដោយសហចុងចម្លើយ៖ សហចុងចម្លើយពិតជាបានចុះកិច្ចសន្យាទទួលប្រាក់កម្ចីពីដើមចោទ ដែលមានប្រាក់សរុបចំនួន ១៥,០០០ ដុល្លារ (មួយម៉ឺនប្រាំពាន់ដុល្លារអាមេរិក) ពិតមែន ប៉ុន្តែសហចុងចម្លើយបានបញ្ជូលទៅក្រុមហ៊ុនដើម្បីធ្វើការវិនិយោគមិនបានយកប្រាក់នេះមកប្រើប្រាស់ផ្ទាល់ខ្លួនទេ ។

## សំអាងហេតុ

យល់ឃើញថា ៖ បណ្តឹងលេខ ៧២ បអស ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៤ របស់ដើមចោទឈ្មោះ [redacted] ណារិន ដែលមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិធ្វើឡើងមានលក្ខណៈត្រឹមត្រូវតាមមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ ដែលសាលាដំបូងខេត្តសៀមរាប អាចទទួលដោះស្រាយ និងវិនិច្ឆ័យបណ្តឹងនេះតាមបញ្ញាតិមាត្រា ៨ និងមាត្រា ៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

យល់ឃើញថា ៖ ដើមចោទបានប្តឹងទាមទារឲ្យសហចុងចម្លើយសងប្រាក់ដើមចំនួន ២០,៣៧៥ដុល្លារ ( ពីរម៉ឺនបីរយចិតសិបប្រាំដុល្លារអាមេរិក ) ។ ប៉ុន្តែបើពិនិត្យទៅលើការអះអាងរបស់ដើមចោទថា ដើមចោទបានយល់ព្រមចុះកិច្ចសន្យាផ្តល់ប្រាក់កម្ចីជាមួយសហចុងចម្លើយចំនួន ២លើក លើកទី១ ចំនួន ៥,០០០ដុល្លារ ( ប្រាំពាន់ដុល្លារអាមេរិក ) លើកទី២ ចំនួន ១០,០០០ដុល្លារ( មួយម៉ឺនដុល្លារអាមេរិក ) សរុបចំនួន ១៥,០០០ដុល្លារ ( មួយម៉ឺនប្រាំពាន់ដុល្លារអាមេរិក ) ហើយសហចុងចម្លើយក៏បានទទួលស្គាល់ផងដែរ ។ ដូច្នេះការប្តឹង



Scanned with CamScanner

ទាមទារប្រាក់ដើមរបស់ដើមចោទ មានចំនួនលើសពីកិច្ចសន្យាផ្ដល់ប្រាក់កម្ចីរវាងដើមចោទ និងសហចុងចម្លើយ គប្បីតុលាការធ្វើការពិចារណា និងសម្រេចអំពីការទាមទាររបស់ដើមចោទ ។

យល់ឃើញថា ៖ ការប្ដឹងទាមទាររបស់ដើមចោទ ដែលយកប្រាក់ដើមចំនួន ១៥,០០០ ដុល្លារ ( មួយម៉ឺនប្រាំពាន់ដុល្លារអាមេរិក ) បូកបន្ថែមលើទៅការប្រាក់ចំនួន ៥,៣៧៥ ( ប្រាំពាន់បីរយចិតសិបប្រាំដុល្លារអាមេរិក ) ពីសហចុងចម្លើយ ពុំមានមូលហេតុត្រឹមត្រូវតាមច្បាប់គប្បីច្រានចោល ។

យល់ឃើញថា ៖ ការអះអាងរបស់ចុងចម្លើយដែលថា សហចុងចម្លើយពិតជាបានចុះកិច្ចសន្យាទទួលប្រាក់កម្ចីពីដើមចោទ ដែលមានប្រាក់សរុបចំនួន ១៥,០០០ ដុល្លារ ( មួយម៉ឺនប្រាំពាន់ដុល្លាអាមេរិក ) ពិតមែន ប៉ុន្តែសហចុងចម្លើយបានបញ្ចូលទៅក្រុមហ៊ុនដើម្បីធ្វើការវិនិយោគមិនបានយកប្រាក់នេះមកប្រើប្រាស់ផ្ទាល់ខ្លួនទេ ។ ប៉ុន្តែបើពិនិត្យទៅលើកិច្ចសន្យាផ្ដល់ប្រាក់កម្ចីចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៣ និងកិច្ចសន្យាផ្ដល់ប្រាក់កម្ចីចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ គឺបានធ្វើឡើងរវាងដើមចោទ និងសហចុងចម្លើយតែប៉ុណ្ណោះ គប្បីតុលាការសម្រេចឲ្យសហចុងចម្លើយសងប្រាក់គ្រប់ចំនួនឲ្យទៅដើមចោទវិញ ។

យល់ឃើញថា ៖ ការព្រមព្រៀងរបស់គូភាគីលើអត្រាការប្រាក់ប្រចាំខែចំនួន ៤% លើប្រាក់ដើមចំនួន ៥,០០០ដុល្លារ ( ប្រាំពាន់ដុល្លារអាមេរិក) យោងតាមកិច្ចសន្យាផ្ដល់ប្រាក់កម្ចីចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៣ និងអត្រាការប្រាក់ប្រចាំខែ ៥% លើប្រាក់ដើមចំនួន ១០,០០០ ដុល្លារ ( មួយម៉ឺនដុល្លារអាមេរិក ) យោងតាមកិច្ចសន្យាផ្ដល់ប្រាក់កម្ចីចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ មានចំនួនលើសច្បាប់កំណត់ គប្បីតុលាការសម្រេចឲ្យសហចុងចម្លើយ បង់ការប្រាក់តាមច្បាប់ដោយអនុវត្តតាមប្រកាសស្ដីពីអត្រាការប្រាក់ដែលត្រូវបានកម្រិត លេខ ១២៨ កយ.ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១ របស់ក្រសួងយុត្តធម៌ ត្រង់ប្រការ ១ ដែលត្រូវបានកំណត់មិនឲ្យលើសពី ១៨% ក្នុងមួយឆ្នាំ ។

យល់ឃើញថា ៖ គិតចាប់ពីថ្ងៃផ្ដល់ប្រាក់កម្ចីទៅឲ្យសហចុងចម្លើយ លើកទី០១ ប្រាក់ដើមចំនួន ៥,០០០ដុល្លារ ( ប្រាំពាន់ដុល្លារអាមេរិក) យោងតាមកិច្ចសន្យាផ្ដល់ប្រាក់កម្ចីចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២៣ សហចុងចម្លើយខកខានមិនបានបង់ការប្រាក់ឲ្យទៅដើមចោទចាប់ពីថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣ និងលើកទី២ ប្រាក់ដើមចំនួន ១០,០០០ ដុល្លារ ( មួយម៉ឺនដុល្លារអាមេរិក ) យោងតាមកិច្ចសន្យាផ្ដល់ប្រាក់កម្ចីចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ សហចុងចម្លើយ ខកខានមិនបានបង់ការប្រាក់ឲ្យទៅដើមចោទចាប់ពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ សហចុងចម្លើយក៏ពុំមានភស្តុតាងណាមួយជាសំអាងបញ្ជាក់ថា បានបង់ការប្រាក់ឲ្យទៅដើមចោទដែរ ហេតុនេះតុលាការ និងសម្រេចឲ្យសហចុងចម្លើយបង់ការប្រាក់ទៅឲ្យដើមចោទតាមច្បាប់កំណត់។

យល់ឃើញថា ៖ ការទាមទារបង្គាប់ឲ្យសហចុងចម្លើយសងសំណងជម្ងឺចិត្តចំនួន ១០,០០០,០០០ រៀល ( ដប់លានរៀល) ឃើញថាការទាមទាររបស់ដើមចោទមានចំនួនច្រើន និងមិនមានវិក័យបត្រលើការចំណាយឲ្យបានច្បាស់លាស់ដាក់មកតុលាការពិនិត្យ ។ ហើយភាគីសហចុងចម្លើយក៏មានព្យសនកម្មដូចគ្នា ។ ហេតុនេះ គប្បីតុលាការពិចារណាពីចំនួននៃការទាសំណងនេះ ឲ្យស្របតាមស្ថានភាពជាក់ស្ដែង ដើម្បីគោរពតាមគោលការណ៍សមភាពរវាងភាគីនៃកិច្ចសន្យា ។



Scanned with CamScanner

យល់ឃើញថា ៖ ការចំណាយលើប្រាក់ប្រដាប់ក្តីតុលាការជាបន្ទុករបស់ភាគីចាញ់ក្តី ស្របតាមបញ្ញត្តិមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

## សេចក្តីសម្រេចបញ្ចប់

១-ឲ្យសហចុងចម្លើយឈ្មោះ [redacted] ផៃរ៉េត និងឈ្មោះ [redacted] ប៊ុនធឿន រួមគ្នាសងប្រាក់ដើម ចំនួន ១៥,០០០ដុល្លារ ( មួយម៉ឺនប្រាំពាន់ដុល្លារអាមេរិក ) ឲ្យទៅដើមចោទឈ្មោះ [redacted] ណារិន ។

២-ឲ្យសហចុងចម្លើយឈ្មោះ [redacted] ផៃរ៉េត និងឈ្មោះ [redacted] ប៊ុនធឿន រួមគ្នាសង ការប្រាក់ចំនួន ១៨% ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន ៥,០០០ដុល្លារ ( ប្រាំពាន់ដុល្លារអាមេរិក ) គិតចាប់ពីថ្ងៃខកខានមិនបានសង ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៣ រហូតដល់ថ្ងៃសងប្រាក់ដើម ឲ្យទៅដើមចោទគ្រប់ចំនួន និងការប្រាក់ចំនួន ១៨% ក្នុងមួយឆ្នាំ លើប្រាក់ដើមចំនួន ១០,០០០ ដុល្លារ ( មួយម៉ឺនដុល្លារអាមេរិក ) គិតចាប់ពីថ្ងៃខកខានមិនបានសង ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៣ រហូតដល់ថ្ងៃសងប្រាក់ដើមឲ្យទៅដើមចោទគ្រប់ចំនួន ឲ្យទៅដើមចោទឈ្មោះ [redacted] ណារិន។

៣-បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] ផៃរ៉េត និងឈ្មោះ [redacted] ប៊ុនធឿន រួមគ្នា បង់សោហ៊ុយការខូចខាតពេលវេលា និងសេវាកម្មមេធាវីសរុបជាប្រាក់ចំនួន ៤,០០០,០០០ រៀល ( បួនលានរៀល ) ឲ្យទៅដើមចោទឈ្មោះ [redacted] ណារិន សុំលើសពីនេះលើកចោល ។

៤-ប្រាក់ប្រដាប់ក្តីតុលាការជាបន្ទុករបស់ភាគីចុងចម្លើយ ។

សាលក្រមនេះ បានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៤ និងប្រកាសសាលក្រមនៅថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៤ ពេលរសៀល នៅចំពោះ មុខដើមចោទឈ្មោះ [redacted] ណារិន និងសហចុងចម្លើយឈ្មោះ [redacted] ប៊ុនធឿន កំបាំងមុខសហចុងចម្លើយ ឈ្មោះ [redacted] ផៃរ៉េត ។

ទុកសិទ្ធិឲ្យគូភាគីប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

ថ្ងៃពុធ ១ កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស២៥៦៧
សៀមរាប, ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២៤
**ចៅក្រម**
ហត្ថលេខា និងត្រា: [redacted]

**បានឃើញ**
**ចៅក្រម**
[redacted]

-បានចម្លងត្រឹមត្រូវតាមច្បាប់ដើម-
ថ្ងៃព្រហស្បតិ៍ ៩កើត ខែពិសាខ ឆ្នាំរោង ឆស័ក ព.ស២៥៦៧
សៀមរាប, ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ២០២៤
**ក្រឡាបញ្ជី**
[redacted]



Scanned with CamScanner